# 16 시간이 있을 때 주로 테니스를 치러 가요

ពេលទំនេរជាធម្មតា ខ្ញុំទៅលេងវាយតេនីស

**학습 안내** ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការនិយាយពីចំណង់ចំណូលចិត្ត |
| □ វេយ្យាករណ៍ | -(으)ㄹ 때, -(으)러 가다 |
| □ ពាក្យថ្មី | ចំណង់ចំណូលចិត្ត, កីឡា |
| □ ព័ត៌មាន · វប្បធម៌ | កម្មវិធីសកម្មភាពចំណង់ចំណូលចិត្ត |

## 대화 1 ការសន្ទនា ១

Track 52

ខាងក្រោមនេះ គឺជាការសន្ទនារវាងស៊ូរូ និង ធូអាន់។ ឥឡូវនេះ ពួកគាត់ទាំងពីរ កំពុងនិយាយគ្នាអំពីចំណង់ចំណូលចិត្ត។ ដំបូង សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន បន្ទាប់មកចូរថាតាម។

투안 수루 씨는 취미가 뭐예요?
ស៊ូរូ, តើអ្នកមានចំណង់ចំណូលចិត្តអ្វីដែរ?

수루 제 취미는 독서예요.
ចំណង់ចំណូលចិត្តរបស់ខ្ញុំ គឺការអាន។
투안 씨는 취미가 뭐예요?
ចុះចំណង់ចំណូលចិត្តរបស់ធូអាន់វិញ គឺជាអ្វី?

투안 전 낚시를 좋아해요.
ខ្ញុំចូលចិត្តស្ទូចត្រី។
그래서 시간이 있을 때 낚시하러 자주 가요.
ដូច្នេះហើយ ពេលទំនេរ ខ្ញុំឧស្សាហ៍ទៅស្ទូចត្រី។

**취미 ចំណង់ចំណូលចិត្ត**
សកម្មភាពដែលចូលចិត្តធ្វើ
- 제 취미는 낚시예요.
  ចំណង់ចំណូលចិត្តរបស់ខ្ញុំ គឺការស្ទូចត្រី។
- 칸 씨는 취미가 많아요.
  លោកខាន់ មានចំណង់ចំណូលចិត្តច្រើន។

**시간이 있다 ⇔ 시간이 없다**
ទំនេរ(មានពេល) ⇔ មិនទំនេរ(គ្មានពេល)
- 가: 월요일에 시간이 있어요?
  តើថ្ងៃច័ន្ទ អ្នកទំនេរឬទេ?
  나: 미안해요. 월요일에는 바빠서 시간이 없어요.
  សុំទោស។ ពីព្រោះតែខ្ញុំរវល់នៅថ្ងៃច័ន្ទ ខ្ញុំមិនទំនេរនោះទេ។
- 언제 시간이 있어요?
  តើពេលណា ទើបអ្នកទំនេរ?

តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬ? អញ្ចឹង សូមឆ្លើយនឹងសំនួរខាងក្រោម។

1. 수루 씨의 취미는 뭐예요? តើចំណង់ចំណូលចិត្តរបស់ ស៊ូរូ គឺជាអ្វី?
2. 투안 씨는 시간이 있을 때 뭐 해요? តើនៅពេលទំនេរ ធូអាន់ ធ្វើអ្វី?

정답 1. 독서예요. 2. 낚시하러 가요.

**Tip 빈도 부사** គុណកិរិយាសព្ទពិសេស

· 항상/언제나 តែងតែ/គ្រប់ពេល · 주로/보통 ជាធម្មតា/ជាទូទៅ · 자주 ញឹកញាប់(ឧស្សាហ៍) · 가끔 ម្តងម្កាល

## 어휘 1 ពាក្យថ្មី ១ | 취미 ចំណង់ចំណូលចិត្ត



ខាងក្រោមនេះ គឺជាកន្សោមពាក្យទាំងឡាយ ដែលទាក់ទងនឹងចំណង់ចំណូលចិត្ត។
តោះ! យើងទៅមើលទាំងអស់គ្នា ថាមានកន្សោមពាក្យអ្វីខ្លះ។



독서하다
អាន



낚시하다
ស្ទូចត្រី



여행하다
ធ្វើដំណើរកម្សាន្ត



등산하다
ឡើងភ្នំ



사진을 찍다
ថតរូប





외국어를 배우다
រៀនភាសាបរទេស



콘서트를 보다
មើលការប្រគំតន្ត្រី



운동 경기를 보다
មើលការប្រកួតកីឡា



음악을 듣다
ស្តាប់តន្ត្រី



기타를 치다
លេងហ្គីតា



피아노를 치다
លេងព្យាណូ



춤을 추다
រាំ

### ទម្រង់មិនទៀងទាត់ 'ㄷ'

ពាក្យដែលបញ្ចប់ដោយជើងប្រកប ‘ㄷ’ នៅពេលដែលប៉ះជាមួយនឹងស្រៈណាមួយ វានឹងត្រូវបានប្តូរទៅជា ‘ㄹ’។

예) · 듣(다) + 어요 = 들어요 · 걷(다) + 을래요 = 걸을래요



សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 알맞은 표현을 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងកន្សោមពាក្យដែលត្រឹមត្រូវ។

① 

② 

③ 

④ 

㉠ 낚시하다 ㉡ 독서하다 ㉢ 등산하다 ㉣ 여행하다

정답 ① ㉡ ② ㉠ ③ ㉣ ④ ㉢

## 문법 1 វេយ្យាករណ៍ ១ | -(으)ㄹ 때

G16-1

ប្រើភ្ជាប់ជាមួយកិរិយាស័ព្ទ ឬក៏គុណនាម ដើម្បីពិពណ៌នាខណៈពេល ឬក៏រយៈពេលនៃការបន្តធ្វើសកម្មភាពអ្វីមួយ។

| 자음(ព្យញ្ជនៈ) → **-을 때** | 모음(ស្រៈ), 자음 'ㄹ'(ព្យញ្ជនៈ 'ㄹ') → **-ㄹ 때** |
|---|---|
| 읽다 → 읽**을 때** | 자다 → **잘 때**<br>놀다 → **놀 때** |

· 가: 운동을 매일 해요? តើអ្នកហាត់កីឡា រាល់ថ្ងៃមែនទេ?
  나: 아니요, 시간이 **있을 때** 해요. អត់ទេ, ពេលទំនេរ ទើបហាត់។
· 가: 그 사람을 언제 만났어요? តើអ្នកបានជួប មនុស្សម្នាក់នោះនៅពេលណា?
  나: 서울 **여행할 때** 만났어요. ខ្ញុំបានជួប នៅពេលធ្វើដំណើរកម្សាន្ត។



តើអ្នកបានយល់អំពីការប្រើប្រាស់ '-(으)ㄹ 때' ហើយមែនដែរឬទេ? អញ្ចឹងសូមសាកល្បងបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

2. 그림을 보고 〈보기〉처럼 '-(으)ㄹ 때'를 사용해서 대화를 완성하세요.
   សូមមើលរូបភាព រួចហើយចូរប្រើប្រាស់ '-(으)ㄹ 때' មកបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기



가: 날씨가 좋을 때 뭐 해요? នៅពេលអាកាសធាតុល្អ តើអ្នកធ្វើអ្វី?
나: 등산해요. ឡើងភ្នំ។

1) 
가: ____________________ 뭐 해요?
나: 집에서 책을 읽어요.

2) 
가: ____________________ 뭐 해요?
나: 노래를 불러요.

3) 
가: ____________________ 뭐 해요?
나: 음악을 들어요.

4) 
가: ____________________ 뭐 해요?
나: 많이 자요.

정답 1) 비가 올 때 2) 기분이 좋을 때 3) 화가 날 때 4) 피곤할 때

## 대화 2 ការសន្ទនា ២

Track 53



មីនស៊ូ និង រីហាន់ កំពុងតែនិយាយគ្នាអំពីសកម្មភាពដែលពួកគេធ្វើនៅថ្ងៃចុងសប្ដាហ៍។ តើពួកគេកំពុងតែសន្ទនាគ្នាអំពីអ្វីទៅ? ជាដំបូង សូមស្ដាប់ការសន្ទនាឲ្យបាន២ដងសិន។ រួចហើយ ចូរថាតាម។

민수 리한 씨는 주말에 보통 뭐 해요?
តើរីហាន់ ជាទូទៅថ្ងៃចុងសប្ដាហ៍ធ្វើអ្វីដែរ?

리한 전 운동을 좋아해서 주로 운동해요.
ដោយសារតែខ្ញុំចូលចិត្តកីឡា ជាធម្មតាខ្ញុំហាត់កីឡា។

민수 무슨 운동을 가장 좋아해요?
តើអ្នកចូលចិត្តកីឡាអ្វីជាងគេ?

리한 축구를 가장 좋아해요.
ខ្ញុំចូលចិត្តបាល់ទាត់ជាងគេ។

민수 그래요? 그러면 내일 저하고 같이 축구하러 갈래요?
ពិតមែនឬ? បើអញ្ចឹង តើថ្ងៃស្អែកចង់ទៅលេងបាល់ទាត់ជាមួយខ្ញុំទេ?

리한 좋아요. 같이 가요.
ល្អ។ ចាំទៅជាមួយគ្នា។
저도 축구를 하고 싶었어요.
ខ្ញុំក៏នឹកចង់លេងបាល់ទាត់ដែរ។

> **N하고 같이 ជាមួយN**
> ប្រើនៅខាងក្រោយនាម(មនុស្ស) ដើម្បីពិពណ៌នាអំពីការធ្វើសកម្មភាពអ្វីមួយជាមួយគ្នា។
> - 오늘은 친구하고 같이 등산해요.
>   ថ្ងៃនេះ ខ្ញុំឡើងភ្នំជាមួយមិត្តភក្តិ។
> - 어제 동생하고 같이 시장에 갔어요.
>   ម្សិលមិញ ខ្ញុំបានទៅផ្សារជាមួយប្អូន។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 리한 씨는 주말에 보통 뭐 해요? តើរីហាន់ ជាទូទៅថ្ងៃចុងសប្ដាហ៍ធ្វើអ្វី?
2. 두 사람은 내일 뭘 할 거예요? តើពួកគាត់ទាំងពីរនាក់ នឹងធ្វើអ្វីនៅថ្ងៃស្អែក?

정답 1. 운동해요. 2. 축구를 할 거예요.

### Tip 취미 활동 동호회 ក្លឹបសកម្មភាពចំណង់ចំណូលចិត្ត

같은 취미를 가진 사람들이 취미 활동을 같이 하는 모임입니다.
គឺជាក្លឹបដែលប្រមូលផ្ដុំទៅដោយអ្នកដែលមានចំណង់ចំណូលចិត្តដូចៗគ្នា ដើម្បីធ្វើសកម្មភាពចំណង់ចំណូលចិត្តរួមជាមួយគ្នា។


축구 동호회
ក្លឹបបាល់ទាត់


등산 동호회
ក្លឹបឡើងភ្នំ


사진 동호회
ក្លឹបរូបថត


요리 동호회
ក្លឹបចម្អិនអាហារ

## 어휘 2 ពាក្យថ្មី ២ | 운동 កីឡា



តោះ! យើងមើលទាំងអស់គ្នា ថាតើមានពាក្យអ្វីខ្លះដែលពិពណ៌នាទាក់ទងនឹងវិស័យកីឡា?



축구하다
លេងបាល់ទាត់



농구하다
លេងបាល់បោះ



야구하다
លេងបេស្បល



수영하다
ហែលទឹក



테니스를 치다
វាយតេនីស



배드민턴을 치다
វាយសី



볼링을 치다
លេងប៊ូលិង



골프를 치다
វាយកូនហ្គោល



스케이트를 타다
លេងជិះស្គី(ប្រើស្បែកជើង)



스키를 타다
លេងជិះស្គីទឹកកក



자전거를 타다
ជិះកង់



សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកចូរសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 알맞은 표현을 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងកន្សោមពាក្យដែលត្រឹមត្រូវ។

① 

② 

③ 

④ 

㉠ 수영하다　㉡ 축구하다　㉢ 농구하다　㉣ 야구하다

정답 ① ㉡ ② ㉢ ③ ㉣ ④ ㉠

## 문법 2 វេយ្យាករណ៍ ២ | -(으)러 가다/오다

G16-2

យើងប្រើប្រាស់ទម្រង់នេះ ភ្ជាប់ជាមួយកិរិយាស័ព្ទ ដើម្បីពិពណ៌នាពីការធ្វើដំណើរទៅកាន់គោលដៅណាមួយ។ '- (으) 러' ត្រូវបានប្រើជាមួយកិរិយាស័ព្ទមានចលនា ដែលមានដូចជា៖ '나가다, 나오다, 들어가다, 들어오다, 올라가다, 올라오다, 내려가다, 내려오다, 다니다' ជាដើម។

| 자음(ព្យញ្ជនៈ) → **-으러 가다/오다** | 모음(ស្រៈ), 자음 'ㄹ'(ព្យញ្ជនៈ 'ㄹ') → **-러 가다/오다** |
|---|---|
| 찾다 → 찾**으러 가다/오다** | 쉬다 → 쉬**러 가다/오다**<br>놀다 → 놀**러 가다/오다** |

- 주말에 친구하고 같이 **운동하러 갈 거예요**. ថ្ងៃចុងសប្តាហ៍ ខ្ញុំនឹងទៅហាត់ប្រាណជាមួយមិត្តភក្តិ។
- 가: 시간 있을 때 뭐 해요? តើពេលទំនេរ អ្នកធ្វើអ្វី?
  나: 주로 사진 **찍으러 가요**. ជាធម្មតា ខ្ញុំទៅថតរូប។

យើងមិនអាចប្រើប្រាស់ '-(으)러' បូកជាមួយនិងកាល '-았/었-', '-겠-' បាននោះទេ។



តើអ្នកបានយល់អំពីការប្រើប្រាស់វេយ្យាករណ៍ '-(으)러 가다/오다' ហើយមែនដែរឬទេ? អញ្ចឹងសូមមើលរូបភាព បន្ទាប់មកចូរបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

2. 그림을 보고 〈보기〉처럼 '-(으)러 가다'를 사용해서 대화를 완성하세요.
សូមមើលរូបភាព រួចហើយចូរប្រើ '-(으)러 가다' មកបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기



가: 시간이 있을 때 뭐 해요? តើនៅពេលទំនេរ អ្នកធ្វើអ្វី?
나: 축구하러 가요. ខ្ញុំទៅលេងបាល់ទាត់។

1) 

가: 시간이 있을 때 뭐 해요?
나: ________________________.

2) 

가: 시간이 있을 때 뭐 해요?
나: ________________________.

3) 

가: 시간이 있을 때 뭐 해요?
나: ________________________.

4) 

가: 시간이 있을 때 뭐 해요?
나: ________________________.

정답 1) 농구하러 가요 2) 테니스를 치러 가요 3) 골프를 치러 가요 4) 자전거를 타러 가요

## 활동 សកម្មភាព

〈보기〉처럼 친구들의 취미를 조사해 보세요.
សូមធ្វើការសាកសួរអំពីចំណង់ចំណូលចិត្តរបស់មិត្តភក្តិរបស់អ្នកដូចទៅនឹងឧទាហរណ៍ខាងក្រោម។

보기

가: 리한 씨는 취미가 뭐예요? តើចំណង់ចំណូលចិត្តរបស់ រីហាន់ គឺជាអ្វី?
나: 제 취미는 요리예요. ចំណង់ចំណូលចិត្តរបស់ខ្ញុំ គឺការចម្អិនអាហារ។
가: 언제 요리해요? តើអ្នកចម្អិនអាហារនៅពេលណា?
나: 시간이 있을 때 가끔 요리해요. ខ្ញុំចម្អិនអាហារម្ដងម្កាល នៅពេលទំនេរ។

| | 이름 ឈ្មោះ | 취미 ចំណង់ចំណូលចិត្ត | 언제 ពេលណា |
|---|---|---|---|
| 보기 | 리한 | 요리<br>ការចម្អិនអាហារ | 시간 있을 때 가끔<br>ម្ដងម្កាល នៅពេលទំនេរ |
| 1) | 투안 | 등산<br>ការឡើងភ្នំ | 기분이 안 좋을 때<br>នៅពេលមានអារម្មណ៍មិនល្អ |
| 2) | | | |
| 3) | | | |
| 4) | | | |
| 5) | | | |

## 퀴즈 លំហាត់តេស្តសាកល្បង

✚ 다음 문장을 보고 생각나는 운동을 이야기해 보세요.
សូមមើលប្រយោគខាងក្រោមហើយចូរនិយាយអំពីកីឡាដែលអ្នកនឹកឃើញ។

공으로 하는 운동이에요. គឺជាកីឡាដែលលេងដោយប្រើបាល់។

공에 날개가 있어요. នៅនឹងបាល់ មានស្លាប។

두 사람 이상 할 수 있어요. អាចលេងចាប់ពីមនុស្ស ២នាក់ឡើង។

정답 배드민턴

## 정보 ព័ត៌មាន

# 취미 활동 프로그램

កម្មវិធីសកម្មភាពចំណង់ចំណូលចិត្ត

각 지역의 복지관, 외국인근로자센터, 외국인력지원센터, 다문화지원센터 등에서는 외국인들의 즐거운 한국생활을 위해 다양한 교육 프로그램을 지원하고 있습니다. 한국어교육, 컴퓨터, 태권도 프로그램을 통하여 취미 활동을 즐길 수 있습니다.

មជ្ឈមណ្ឌលសុខុមាលភាព មជ្ឈមណ្ឌលពលករបរទេស មជ្ឈមណ្ឌលគាំទ្រកម្លាំងពលកម្មបរទេស និងមជ្ឈមណ្ឌលគាំទ្រពហុវប្បធម៌ក្នុងតំបន់នីមួយៗ ផ្តល់នូវកម្មវិធីអប់រំផ្សេងៗសម្រាប់ជនបរទេសដើម្បីភាពរីករាយក្នុងការរស់នៅរបស់ពួកគេនៅក្នុងប្រទេសកូរ៉េ។ ពួកគេអាចរីករាយជាមួយនឹងចំណង់ចំណូលចិត្តរបស់គេតាមរយៈការអប់រំភាសាកូរ៉េ កុំព្យូទ័រ និងកម្មវិធីកីឡាតៃក្វាន់ដូជាដើម។




한국어 수업
ថ្នាក់រៀនភាសាកូរ៉េ



컴퓨터 수업
ថ្នាក់រៀនកុំព្យូទ័រ




태권도 수업
ថ្នាក់រៀនតៃក្វាន់ដូ



요리 수업
ថ្នាក់រៀនចម្អិនអាហារ

# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK



សំណួរទី១និងទី២គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសពាក្យដែលត្រឹមត្រូវ ។
សូមស្តាប់ដោយយកចិត្តទុកដាក់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

[1~2] 다음 그림을 보고 알맞은 것을 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

Track 54

1. 

① ② ③ ④

2. 

① ② ③ ④



បន្ទាប់មកនេះ គឺជាការស្តាប់សំណួរ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។
មុននឹងស្តាប់ សូមពិនិត្យមើលចម្លើយជាមុនសិន។

[3~5] 질문을 듣고 알맞은 대답을 고르십시오.
សូមស្តាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

3. ① 독서예요. ② 독서할래요.
③ 독서 안 해요. ④ 독서하고 싶어요.

4. ① 낚시하러 가요. ② 제 취미는 낚시예요.
③ 친구하고 같이 해요. ④ 시간이 있을 때 해요.

5. ① 일요일에 해요. ② 테니스 치러 가요.
③ 내일이 주말이에요. ④ 음악을 들을 때 기분이 좋아요.



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្ដាប់

1. ① 여: 독서 ការអាន ② 여: 낚시 ការស្ទូចត្រី
   ③ 여: 여행 ការដើរកម្សាន្ត ④ 여: 등산 ការឡើងភ្នំ
2. ① 남: 축구 កីឡាបាល់ទាត់ ② 남: 농구 កីឡាបាល់បោះ
   ③ 남: 야구 កីឡាបេស្បល ④ 남: 수영 កីឡាហែលទឹក
3. 여: 취미가 뭐예요? តើចំណង់ចំណូលចិត្តរបស់អ្នក គឺជាអ្វី?
4. 남: 주로 언제 낚시를 해요? ជាធម្មតា តើអ្នកស្ទូចត្រីពេលណា?
5. 여: 주말에 보통 뭐 해요? តើថ្ងៃចុងសប្ដាហ៍ ជាទូទៅ អ្នកធ្វើអ្វី?

정답 1. ② 2. ③ 3. ① 4. ④ 5. ②

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-16

1. 이 사람은 무엇을 하고 있습니까? តើមនុស្សម្នាក់នេះ កំពុងតែធ្វើអ្វី?



① ② ③ ④

2. 대화를 듣고 질문에 알맞은 것을 고르십시오.
   ចូរស្ដាប់ការសន្ទនា ហើយជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

   여자는 이번 주말에 무엇을 하겠습니까? តើស្ត្រីម្នាក់នេះ នឹងធ្វើអ្វីនៅថ្ងៃចុងសប្ដាហ៍នេះ?

   ① 기타를 배울 겁니다. ② 한국어를 가르쳐 줄 겁니다.
   ③ 일이 많아서 출근을 할 겁니다. ④ 휴게실에서 텔레비전을 볼 겁니다.

## 확장 연습 듣기 대본 អត្ថបទស្ដាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. ① 남: 요리를 배워요. រៀនចម្អិនអាហារ។ ② 남: 컴퓨터를 배워요. រៀនកុំព្យូទ័រ។
   ③ 남: 태권도를 배워요. រៀនតៃក្វាន់ដូ។ ④ 남: 한국어를 배워요. រៀនភាសាកូរ៉េ។
2. 여: 건우 씨, 요즘도 바빠요? លោកខន់អ៊ូ! តើសព្វថ្ងៃនេះនៅតែរវល់មែនទេ?
   남: 어제까지 일이 많아서 좀 바빴어요. ត្រឹមម្សិលមិញ ដោយសារមានការងារច្រើន ដូច្នេះរាងរវល់បន្តិច។ តែចាប់ពីថ្ងៃនេះ
   오늘부터 다음 주말까지는 별로 바쁘지 않아요. រហូតដល់ថ្ងៃចុងសប្ដាហ៍អាទិត្យក្រោយ មិនសូវជារវល់នោះទេ។
   여: 그래요? 제가 기타를 배워 보려고 하는데 혹시 좀 가르쳐 줄 수 있어요?
   អញ្ចឹងឬ? ខ្ញុំមានបំណងចង់រៀនលេងហ្គីតា តើអាចជួយបង្រៀនខ្ញុំបានទេ?
   남: 그럼요. 주말에 휴게실에서 만나요. 제가 가르쳐 드릴게요.
   ប្រាកដជាបាន! បើអញ្ចឹង ចាំជួបគ្នានៅថ្ងៃចុងសប្ដាហ៍ នៅបន្ទប់សម្រាក។ ចាំខ្ញុំជួយបង្រៀន។

정답 1. ② 2. ①

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



សំណួរទី១ និងទី២ គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសប្រយោគដែលត្រឹមត្រូវ ។
សូមជ្រើសរើសប្រយោគដែលត្រឹមត្រូវទៅនឹងរូបភាព។

[1~2] 다음 그림을 보고 맞는 문장을 고르십시오. ចូរមើលរូបភាពខាងក្រោម ហើយជ្រើសរើសប្រយោគដែលត្រឹមត្រូវ។

1. 

① 피아노를 쳐요. ② 음악을 들어요.
③ 사진을 찍어요. ④ 외국어를 배워요.

2. 

① 축구해요. ② 수영해요.
③ 테니스를 쳐요. ④ 자전거를 타요.



សំណួរបន្ទាប់ គឺជាជាការអានប្រយោគឬការសន្ទនា ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវដើម្បីបំពេញចន្លោះ។ សូមរំលឹកពីអ្វីដែលបានរៀនរួចមកហើយបណ្តើរ បន្ទាប់មកសាកល្បងដោះស្រាយសំណួរបណ្តើរ។

[3~5] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3. 제 취미는 낚시예요. 저는 낚시가 정말 ________. 그래서 시간이 있을 때 항상 낚시를 하러 가요.
ចំណង់ចំណូលចិត្តរបស់ខ្ញុំគឺការស្ទូចត្រី។ ខ្ញុំពិតជាចូលចិត្តការស្ទូចត្រីណាស់។ ដូច្នេះហើយ រៀងរាល់ពេលទំនេរ ខ្ញុំតែងតែទៅស្ទូចត្រី។

① 슬퍼요 ② 좋아요 ③ 맛있어요 ④ 재미없어요

4. 가: ____________________? តើចុងសប្តាហ៍ ជាទូទៅអ្នកធ្វើអ្វី?
나: 전 주로 자전거를 타러 가요. ជាធម្មតា ខ្ញុំទៅជិះកង់។

① 왜 자전거를 타요 ② 주말에 보통 뭐 해요
③ 누구하고 자전거를 타요 ④ 이번 주말에 시간 있어요

5. 가: 무슨 ________을 좋아해요? តើអ្នកចូលចិត្តកីឡាអ្វី?
나: 전 축구를 좋아해요. ខ្ញុំចូលចិត្តកីឡាបាល់ទាត់។

① 음식 ② 계절 ③ 요일 ④ 운동

정답 1. ③ 2. ④ 3. ② 4. ② 5. ④



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~2] 다음 그림을 보고 맞는 문장을 고르십시오.

សូមមើលរូបភាពខាងក្រោមនេះ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1.



① 골프 ② 농구
③ 수영 ④ 축구

2.



① 스키 ② 테니스
③ 배드민턴 ④ 스케이트

[3~4] 빈칸에 들어갈 가장 알맞은 것을 고르십시오.

ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3. 제 취미는 등산입니다. 주말이면 자주 가까운 산으로 등산을 ______ 갑니다.

ចំណង់ចំណូលចិត្តរបស់ខ្ញុំគឺការឡើងភ្នំ។ អោយតែជាថ្ងៃចុងសប្តាហ៍ ភាគច្រើនគឺខ្ញុំទៅឡើងភ្នំ នៅភ្នំជិតៗហ្នឹង។

① 하고 ② 하러 ③ 하면 ④ 해서

4. 저는 한국에 ______ 비행기를 탈 겁니다. 처음이라서 조금 무섭지만 재미있을 것 같습니다.

ពេលទៅប្រទេសកូរ៉េ ខ្ញុំនឹងជិះយន្តហោះទៅ។ ដោយសារតែនេះគឺជាលើកដំបូង ខ្ញុំប្រហែលជាអាចនឹងភ័យខ្លាចបន្តិច ប៉ុន្តែមើលទៅសប្បាយ។

① 가고 ② 가려 ③ 갈 때 ④ 간 후

정답 1. ① 2. ④ 3. ② 4. ③

## 발음 ការបញ្ចេញសម្លេង

P-05

### សូមស្តាប់ដោយយកចិត្តទុកដាក់ រួចហើយចូរថាតាម។

ចំពោះតួអក្សរកូរ៉េដែលបញ្ចេញសម្លេងនៅចុងអណ្តាត គឺមានតែ ‘ㄹ’ មួយគត់។ ‘ㄹ’ នេះ នៅពេលដែលវាស្ថិតនៅចន្លោះស្រៈគឺវាបញ្ចេញសម្លេងជា [r] ហើយនៅពេលដែលវានៅចុងនៃចុងព្យាង្គណាមួយបញ្ចេញសម្លេងជា [l]វិញ។

(1) 다리, 우리, 노래, 소리

(2) 달, 말, 쌀, 솔, 하늘